# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៥ សសរ

## សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសំរួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរ នៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ២២ សសរ ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង សំរាប់ដោះស្រាយបាតុភាពអសកម្មមួយចំនួន នៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត
- យោងរបាយការណ៍របស់ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៥
- យោងចំណាររបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០០៥
- យោងប្រសាសន៍ផ្ទាល់មាត់របស់សម្តេចនាយករដ្ឋមន្ត្រី នៅថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៥

## សំរេច

**ប្រការ១:** បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីសំរួលដល់ការធ្វើដំណើរ និងការដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរ នៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត ដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តមនាយឧត្តមសេនីយ៍ **ហុក ឡុងឌី** | អគ្គស្នងការនគរបាលជាតិ | ប្រធាន |
| ២-ឯកឧត្តម **ថោង ខុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តម **គង់ វិបុល** | រដ្ឋលេខាធិការទី១ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤-ឯកឧត្តមឧត្តមសេនីយ៍ឯក **សុខ ផល** | អគ្គស្នងការរងនគរបាលជាតិ | អនុប្រធាន |
| ៥- ឯកឧត្តម **ម៉ុន ស៊ីយ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦-ឯកឧត្តម **អ៊ុក ចាន់** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៧-ឯកឧត្តម **ម៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ៨-ឯកឧត្តម **ស្វ មារី** | អគ្គលេខាធិការនៃអាជ្ញាធរជាតិទេសចរណ៍កម្ពុជា | សមាជិក |
| ៩-ឯកឧត្តម **ឌុច ចនធីតូ** | អគ្គនាយករៀបចំដែនដី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១០-ឯកឧត្តម **សក់ សេដ្ឋា** | អគ្គនាយករដ្ឋបាល នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១១- អភិបាលខេត្តជាប់ព្រំដែនដែលមានច្រកទ្វារអន្តរជាតិ | | សមាជិក |
| ១២-ឯកឧត្តមឧត្តមសេនីយ៍ទោ **ខៀវ សុផាន់ណា** | ប្រធាននាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ | សមាជិក |

**ប្រការ២:** គណៈកម្មការអន្តរក្រសួងនេះ មានមុខងារ និងភារកិច្ចដូចតទៅ:

- ជំរុញអនុវត្តសេចក្តីជូនដំណឹងលេខ៤១៣ សជណ សរ ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី អោយមានប្រសិទ្ធិភាព ដើម្បីរៀបចំរបៀបរៀបរយ សណ្តាប់ធ្នាប់ និងសំរួលការដឹកជញ្ជូន និងការធ្វើដំណើររបស់ភ្ញៀវទេសចរ និងអ្នកដំណើរនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត អោយបានល្អប្រសើរ ។
- សិក្សារៀបចំតំបន់ច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត អោយមានហេដ្ឋា - រចនាសម្ព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រាន់ ដើម្បីសំរួលដល់ការធ្វើដំណើរ និងការដឹកជញ្ជូនអ្នកដំណើរ និងភ្ញៀវទេសចរ។
- លុបបំបាត់ និងបោសសំអាតភាពអសកម្មទាំងឡាយ និងភាពអនាធិបតេយ្យគ្រប់បែបយ៉ាង ដែលនាំអោយប៉ះពាល់ និងរំខានដល់ការធ្វើដំណើរ និងការដឹកជញ្ជូនអ្នកដំណើរ និងភ្ញៀវទេសចរ ។
- បូកសរុបលទ្ធផល និងធ្វើរបាយការណ៍ ដោយលើកយោបល់ជាវិធានការដោះស្រាយជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

**ប្រការ៣:** គណៈកម្មការអន្តរក្រសួងនេះមានលេខាធិការដ្ឋានមួយជាជំនួយការដែលមានទីតាំងនៅអគ្គស្នងការដ្ឋាននគរបាលជាតិ និងមានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គស្នងការនគរបាលជាតិ និងចំណាយថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ៤:** សមាជិកគណៈកម្មការទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងអាចប្រើប្រាស់មន្ត្រីក្នុងអង្គភាពរបស់ខ្លួនបន្ថែមទៅតាមសំណូមពរ និងទំហំការងារជាក់ស្តែង។

**ប្រការ៥ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អាជ្ញាធរជាតិទេសចរណ៍កម្ពុជា អគ្គស្នងការដ្ឋាននគរបាលជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និងរដ្ឋាករ សាលាខេត្ត និងមន្ទីរទេសចរណ៍ខេត្ត ជាប់ព្រំដែនដែលមានច្រកទ្វារអន្តរជាតិ ប្រធាន អនុប្រធាន និងសមាជិកដែលមានរាយនាមក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០

សម្តេចនាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ